ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
ទីក្រុងស្អាត ត្រូវធ្វើឡើងពីយើងទាំងអស់គ្នា

គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
លេខ: ០០៣ សវក.គជវត

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០១៦

# សេចក្តីសម្រេច
## ស្តីពី
## ការកំណត់ "ស្តង់ដារបដិសណ្ឋារកិច្ចល្អក្នុងសេវាសាធារណៈរបស់ក្រុង/ខណ្ឌ បេក្ខភាពក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត"

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍
## និងជាប្រធានគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ មិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦១៤ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៧ អនក្រ/បក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
- បានឃើញសេចក្តីជូនដំណឹងលេខ ៥៦១ សជណ.ផក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់នៃការងារ

ផ្ទះលេខ ៣A ផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ១៦ ៧៣៨ ៤០៣ ទូរសារ: +៨៥៥ ២៣ ៨៨៥ ០១៨

# សម្រេច

**ប្រការ ១._**

ត្រូវបានកំណត់ស្តង់ដា **"បដិសណ្ឋារកិច្ចល្អក្នុងសេវាសាធារណៈរបស់ក្រុង/ខណ្ឌបេក្ខភាពក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត"** សំដៅចូលរួមលើកកម្ពស់ការផ្តល់សេវាសាធារណៈរបស់ក្រុង/ខណ្ឌបេក្ខភាពក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាតឱ្យកាន់តែប្រសើរឡើង ប្រកបដោយភាពកក់ក្តៅស្របតាមអភិក្រម: **"ធ្វើឱ្យបាន ធ្វើឱ្យលឿន ធ្វើឱ្យមានតម្លាភាព"**។

ស្តង់ដាបដិសណ្ឋារកិច្ចល្អក្នុងសេវាសាធារណៈរបស់ក្រុង/ខណ្ឌបេក្ខភាពក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣._**

សមាជិក សមាជិកានៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត អគ្គលេខាធិការ អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត ប្រធាន អនុប្រធានផ្នែក និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត**

**ប្រធាន**

**ថោង ខុន**

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ